# សេចក្តីសន្និដ្ឋានបើករបស់លោកមេធាវី សុន អរុណ

## I. សេចក្តីផ្តើម

១. ថ្ងៃនេះលោក/លោកស្រីបានស្តាប់ឮលោក នួន ជា ថ្លែងដោយខ្លួនគាត់ផ្ទាល់ជាលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ លោក នួន ជា បានសម្រេចធ្វើសេចក្តីថ្លែងនេះ ដោយសារតែគាត់ជឿជាក់ថា វាមានសារៈសំខាន់ដល់ប្រជាជនកម្ពុជា ស្តាប់ឮនូវការពិត។ លោក នួន ជា មិនចង់ដោះសារយករួចខ្លួនទេ តែគាត់ចង់ពន្យល់ពីខ្លួនគាត់។ មានសៀវភៅជាច្រើននិយាយពីព្រឹត្តិការណ៍នានា ដែលបានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែជាអកុសលសៀវភៅទាំងនោះត្រូវបានសរសេរដោយជនបរទេសទៅវិញ ដែលមានការយល់ដឹងដ៏កម្រិតពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ហើយក៏មានការយល់ដឹងកម្រិតលើអង្គហេតុនានាដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ២៩៧៩ ដែរ។ ម្យ៉ាងវិញទៀត លោក នួន ជា យល់ប្រវត្តិសាស្ត្ររបស់ប្រទេសនេះយ៉ាងច្បាស់ ។ គាត់យល់យ៉ាងច្បាស់ថាតើប្រទេសកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេច នៅពេលដែលខ្មែរក្រហមគ្រប់គ្រងអំណាចនៅឆ្នាំ ១៩៧៥ និងនៅឆ្នាំមុនខ្មែរក្រហមគ្រប់គ្រងអំណាច ។ សំខាន់ជាងនេះទៅទៀតគាត់យល់ពីគោលបំណងរបស់របបមួយដែលគាត់បានចូលរួមបង្កើត ។

២. ថ្ងៃនេះ ខ្ញុំនឹងចែករំលែកជាមួយលោក/ស្រី នូវការកត់សម្គាល់មួយចំនួនដែលសំខាន់ដល់ក្រុមការពារលោក នួន ជា។ ខ្ញុំនឹងនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនពីតំបន់និរតី ទៅកាន់តំបន់ពាយ័ព្យ។ ខ្ញុំនឹងពន្យល់ថាហេតុអ្វីបានជាការផ្លាស់លំនៅប្រជាជន គឺចាំបាច់ដោយផ្អែកលើទិដ្ឋភាពមនុស្សធម៌។ ហើយខ្ញុំនឹងលើកអំណះអំណាងថាការផ្លាស់ទីលំនៅប្រជាជនធ្វើឡើងដោយស្របច្បាប់ បើនិយាយពីទិដ្ឋភាពច្បាប់ ។

៣. ដើម្បីអាចពន្យល់ពីបញ្ហានេះបាន ខ្ញុំនឹងនិយាយដោយសង្ខេបអំពីស្ថានភាពរបស់ប្រទេសកម្ពុជានៅឆ្នាំ ១៩៧៥ និងជាពិសេសស្ថានភាពនៅទីក្រុងភ្នំពេញ ។ ខ្ញុំនឹងពិភាក្សាអំពីតួនាទីរបស់វៀតណាម និងការទម្លាក់គ្រាប់បែករបស់អាមេរិកនៅមុនឆ្នាំ១៩៧៥ ។ ខ្ញុំនឹងពិភាក្សាពីគោលបំណងរបស់កម្ពុជាប្រជាធិបតេយ្យ នៅទូទាំងការផ្លាស់ទីលំនៅប្រជាជន ហើយខ្ញុំនឹងលើកអំណះអំណាងថា ច្បាស់ណាស់កម្ពុជាប្រជាធិបតេយ្យតែងតែបំរើសុខុមលភាពរបស់ប្រជាជនកម្ពុជាជានិច្ច ។

### ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

៤. នួន ជា មិនបានបដិសេធពីការជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅឆ្នាំ ១៩៧៥ ទេ ហើយតាមពិត គាត់អះអាងថាការជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺចាំចាច់ដើម្បីទប់ស្កាត់ភាពទុរ្ភិក្ស (ភាពអត់ឃ្លាន) និងជំងឺរាលដាលបន្ថែមទៀត ។

៥. មានអ្នកសង្កេតការជាច្រើនដែលភាគច្រើនជាជនបរទេស បានលាបពណ៌ការជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា ជាអំពើព្រៃផ្សៃមួយដែលកើតចេញពីមនោគមន៍វិជ្ជានយោបាយមិនសមហេតុផល ។ នេះគឺជាការលាបពណ៌មិនត្រឹមត្រូវមួយទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការជន្លៀសប្រជាជននេះ។ គេត្រូវតែយល់ថាការជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជាអំពើសមហេតុផលមួយរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ដែលយកចិត្តទុកដាក់ពីសុខុមភាពរបស់ទីក្រុង និងប្រជាជនទីក្រុងនេះ ។

៦. នាខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញជាទីកន្លែងដ៏លំបាកវេទនាជាទីបំផុតនៅលើផែនដីនេះ ។ ជាទីក្រុងដែលមានមនុស្សរស់នៅយ៉ាងណែនណាន់ ជាមួយនឹងជនភៀសខ្លួនជាងមួយលាននាក់ ។ មានការកង្វះអង្ករ និងស្បៀងផ្សេងៗយ៉ាងធ្ងន់ធ្ងរ និងជំងឺដង្កាត់ផ្សេងៗបានរីករាលដាល ។ មន្ទីរពេទ្យ និងសេវាសុខាភិបាលសឹងតែមិនដំណើរការទាល់តែសោះ និងមានជំនួយដ៏តិចតួចផ្តល់មកទីក្រុងភ្នំពេញ ។ ការផ្គត់ផ្គង់ស្បៀងដ៏មានកម្រិតពីសហរដ្ឋអាមេរិក ទៅឱ្យរបបពុករលួយ លន់ ណុល ត្រូវបានកាត់ផ្តាច់ភ្លាមៗ បន្ទាប់ពីការចូលកាន់កាប់ទីក្រុងភ្នំពេញ ។ និយាយជារួម ទីក្រុងភ្នំពេញជួបវិបត្តិមនុស្សជាតិយ៉ាងធ្ងន់ធ្ងរនៅខែមេសា ឆ្នាំ១៩៧៥ ។ ចំពោះថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងចំពោះ នួន ជា យល់យ៉ាងច្បាស់ថាភារកិច្ចដ៏សំខាន់បន្ទាប់ពីពួកគេកាន់កាប់ទីក្រុងភ្នំពេញ នោះគឺចិញ្ចឹមអ្នកស្រុកភ្នំពេញ និងប្រជាជនទាំងអស់ ហើយពួកគេមិនបានបណ្តែតបណ្តោយឱ្យខាតបង់ពេលវេលាឡើយ ។

៧. កម្ពុជាប្រជាធិបតេយ្យពិតជាគ្មានមធ្យោបាយចិញ្ចឹមប្រជាជនដ៏ច្រើនលើសលុប ដែលទទួលរងនូវការឈឺចុកចាប់វេទនាក្នុងរយៈពេលខ្លីបានទេ ។ ក្រៅពីជួបនូវវិបត្តិខ្វះស្បៀង និងស្ថានភាពសុខាភិបាលដ៏អាក្រក់ សង្គ្រាមស៊ីវិលក៏បានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេសផងដែរ។ និយាយជាសង្ខេប គេមិនអាចបញ្ជូនស្បៀងចូលទីក្រុងភ្នំពេញក្នុងពេលប្រថុចប្រញ៉ុចបានទេ ។

៨. ហេតុដូច្នេះ ការសម្រេចរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ គឺជាការសម្រេចមួយសាមញ្ញ និងអាចយល់បាន។ ពួកគេសម្រេចជន្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញទៅជនបទស្រុកស្រែ។

មធ្យោបាយនេះមានគុណប្រយោជន៍ពីរ ។ គឺទី១ វានឹងនាំយកប្រជាជនដែលស្រេកឃ្លានពីទីក្រុងភ្នំពេញឲ្យទៅជិតនឹងប្រភពពិតប្រាកដនៃស្បៀង ទី២ ជាត្រឡប់មកវិញប្រជាជនទាំងនេះអាចជួយផលិតស្បៀង ដែលត្រូវបង្កើតឡើងពីចំណុចសូន្យបន្ទាប់សង្គ្រាម។ គ្មានហេតុផលអាក្រក់សម្រាប់ការជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ។ តាមពិត មេដឹកនាំកម្ពុជាប្រជាធិបតេយ្យគ្រាន់តែព្យាយាមថែទាំប្រជាជននៅក្នុងទីក្រុងភ្នំពេញអស់ពីសមត្ថភាពរបស់ពួកគេតែប៉ុណ្ណោះ ។

៩. នៅដំណាក់កាលចាប់ផ្ដើមការជំនុំជម្រះនេះ វាជាការសំខាន់ក្នុងការកត់សម្គាល់ថាអង្គហេតុដែលរៀបរាប់ពីខាងលើដែលបានកើតឡើងជាង ៣៥ ឆ្នាំមកហើយនោះ មិនមែនជាការងាយស្រួលក្នុងការប្រឌិតឡើងដោយ នួន ជា នោះទេ ។ តាមពិត ប្រសិនបើគេពិនិត្យមើលភស្តុតាងនៅក្នុងករណីនេះ គេនឹងយល់ឃើញថាគោលបំណងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ គឺច្បាស់លាស់រួចមកហើយនៅឆ្នាំ១៩៧៥។ ឯកសារផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យដែលនឹងលើកយកមកពិភាក្សាក្នុងពេលជំនុំជម្រះនេះ នឹងបង្ហាញថា ក្ដីកង្វល់ចំពោះប្រជាជនកម្ពុជា និងជាពិសេសស្ថានភាពស្បៀង គឺជាក្ដីកង្វល់ដ៏ចម្បងបំផុតរបស់កម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំនឹងលើកមកនិយាយពីឯកសារទាំងនេះនាពេលបន្តិចទៀត ។

១០. ប៉ុន្តែជាបឋមខ្ញុំត្រូវតែរិះគន់ដល់កិច្ចស៊ើបសួរដោយចៅក្រមស៊ើបអង្កេត។ ការស៊ើបអង្កេតដែលមិនគ្រប់ជ្រុងជ្រោយនេះបានបង្កនូវភាពស្មុគស្មាញយ៉ាងខ្លាំងដល់ក្រុមការពារ លោក នួន ជា ។ តាំងតែពីដំណាក់កាលដំបូងនៃករណីនេះ ក្រុមការពាររបស់ខ្ញុំបានទទួចថាបរិបទទាក់ទងនឹងនឹងការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ មានសារៈសំខាន់ជាទីបំផុតនៅក្នុងការជំនុំជម្រះនេះ ដែលទាមទារឲ្យគេពិនិត្យមើលព្រឹត្តិការណ៍នានា ដែលបានកើតឡើងនៅមុនពេលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចូលកាន់អំណាចនៅកម្ពុជា ។

១១. យើងត្រូវតែពិនិត្យ និងយល់ពីរបបដ៏ពុករលួយ និងព្រៃផ្សៃរបស់ លន់ ណុល ។ យើងត្រូវតែពិនិត្យមើលពីការទម្លាក់បែករបស់អាមេរិក ដែលមិនសម្លាប់តែប្រជាជនស្លូតត្រង់កម្ពុជារាប់សិបពាន់នាក់ប៉ុណ្ណោះទេ តែថែមទាំងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសនិងស្បៀងផងដែរ។ យើងត្រូវតែពិនិត្យស្ថានភាពដ៏អាក្រក់របស់ប្រទេសកម្ពុជាទាំងមូល នៅមុនខែមេសា ឆ្នាំ១៩៧៥ ដែលទទួលរងនូវការបំផ្លិតបំផ្លាញដោយសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ និងដោយគ្មានការដំណើរការប្រព័ន្ធសុខាភិបាល។ យើង

ត្រូវតែពិចារណាការជ្រៀតជ្រែកជាបន្តបន្ទាប់ចូលក្នុងកិច្ចការរបស់កម្ពុជាពីសំណាក់ប្រទេសវៀតណាមនៅមុនឆ្នាំ១៩៧៥ ។

១២. កាលៈទេសៈទាំងអស់នេះពិតជាមិនអាចមិនអើពើបានទេ នៅពេលស៊ើបអង្កេតរបបកម្ពុជាប្រជាធិបតេយ្យ។ គេចាំបាច់ពិនិត្យទិដ្ឋភាពពេញលេញរបស់អង្គហេតុទាំងនេះ ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើសកម្មភាព និងគោលបំណងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅពេលដែលពួកចូលកាន់អំណាច ។ នៅពេលវាយតម្លៃពីអំពើរបស់មេដឹកនាំម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យបញ្ហាថា តើប្រទេសរបស់គាត់ត្រូវបានបំផ្លាញដោយយន្តហោះទម្លាក់គ្រាប់បែក B52 ដែរ ឬអត់ ។ នៅពេលវាយតម្លៃពីអំពើរបស់មេដឹកនាំម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យមើលបញ្ហាថា តើគាត់ត្រួតត្រាទីក្រុងដ៏ស្អាត និងស្រស់ឆើតឆាយដែរ ឬអត់ ឬជាទីក្រុងដែលហៀបតែធ្លាក់ចូលក្នុងភាពអត់ឃ្លានទៅហើយនោះ។ នៅពេលវាយតម្លៃអំពើរបស់មេដឹកនាំម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ គេត្រូវពិនិត្យមើលបញ្ហាថា តើប្រទេសជិតខាងមួយដែលក្នុងករណីនេះ គឺប្រទេសវៀតណាម ពិតជាបានព្យាយាមធ្វើឲ្យអត្ថិភាពប្រទេសមួយដែរ ឬអត់ និយាយសង្ខេប យើងមិនអាចយល់ពីអំពើ និងការខកខានរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានទេ ប្រសិនបើយើងមិនបានពិនិត្យមើលបរិបទខាងប្រវត្តិសាស្ត្រ និងសង្គមសាស្ត្រដែលត្រូវបានអនុវត្តនោះឡើយ ។

១៣. តែបរិបទនេះត្រូវបានបំភ្លេចចោលទាំងស្រុងដោយចៅក្រមស៊ើបអង្កេត នៅក្នុងកិច្ចស៊ើបអង្កេតរបស់ពួកគេ។ ចៅក្រមស៊ើបអង្កេតបានផ្តោតការយកចិត្តទុកដាក់ទាំងស្រុងទៅលើអង្គហេតុដែលកើតឡើងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប៉ុណ្ណោះ ។ ហេតុដូច្នេះ ការស៊ើបអង្កេតនេះមិនគ្រប់ជ្រុងជ្រោយទេ ។

១៤. ដូចដែលបង្ហាញរួចមកហើយ យុទ្ធនាការណ៍ទម្លាប់គ្រាប់បែកដ៏សម្លាប់រង្គាលរបស់អាមេរិកនៅទសវត្សរ៍ឆ្នាំ១៩៧០ ត្រូវបានលើកឡើងយ៉ាងខ្លីនៅក្នុងដីកាដំណោះស្រាយ។ ដោយសារតែចៅក្រមស៊ើបអង្កេតយល់ឃើញថា យុទ្ធនាការណ៍ទម្លាប់គ្រាប់បែកនេះ និងអនុភាពរបស់វាមិនពាក់ព័ន្ធទាំងស្រុងនៅពេលពួកគេវាយតម្លៃព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំក្រោយៗមកទៀតនោះ។ ឧទាហរណ៍មួយទៀតពីដីកាដំណោះស្រាយ គឺស្ថានការណ៍ដ៏អាក្រក់នៅក្នុងទីក្រុងភ្នំពេញ ប៉ុន្មានថ្ងៃនៅមុនខ្មែរក្រហមចូលកាន់កាប់ទីក្រុងនេះនៅមេសា ឆ្នាំ១៩៧៥ ត្រូវបានពិពណ៌នាមិនលើសពី៣ កថាខណ្ឌទេ ហើយដែលកថាខណ្ឌទាំងនេះរៀបរាប់ក្នុងន័យវិជ្ជមានអំពីទីក្រុងភ្នំពេញនាសម័យនោះទៀតផង ។ នេះពិតជាមិនគួរឲ្យជឿទេចំពោះជនទាំងឡាយដែលបានដឹងពីស្ថានការណ៍នៅទីក្រុងភ្នំពេញនាសម័យនោះ។

និយាយជាសង្ខេប ការស៊ើបអង្កេតដោយចៅក្រមស៊ើបអង្កេតមិនបានគ្របដណ្តប់ទៅលើអង្គហេតុដែលពាក់ព័ន្ធក្នុងករណីនេះទេ ។

១៥. លោក/លោកស្រីចៅក្រមអង្គជំនុំជម្រះសាលាដំបូង អាចកែតម្រូវចំណុចខ្វះខាតទាំងនេះ ដោយអនុញ្ញាតមានការស្តាប់ចម្លើយសាក្សីមួយចំនួនដែលពួកយើងខ្ញុំបានស្នើសុំ ។ យើងខ្ញុំចង់ឲ្យស្តាប់ចម្លើយសាក្សី ដែលស្ថិតនៅទីក្រុងភ្នំពេញនៅមុនពេលការចាប់កំណើតរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យពួកគេពន្យល់ពួកយើងថាតើស្ថានភាពនៅក្នុងទីក្រុងភ្នំពេញនៅពេលនោះ វាពិតជាអាក្រក់យ៉ាងដូចម្តេច ។ យើងចង់ស្តាប់ការផ្តល់សក្ខីកម្មរបស់មន្ត្រីយោធាអាមេរិកនៅពេលនោះ ដើម្បីបានឮការវាយតម្លៃរបស់ពួកគេអំពីការខូចខាតដែលបណ្តាលមកពីការវាយប្រហារដោយគ្រាប់ B52 របស់ពួកគេ ។ មិនតែប៉ុណ្ណោះ ពួកយើងចង់ស្តាប់ចម្លើយរបស់សាក្សីដទៃទៀត ដែលអាចផ្តល់បរិបទពាក់ព័ន្ធទៅនឹងសកម្មភាពនានាដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែអង្គជំនុំជម្រះ បានបដិសេធមិនស្តាប់ចម្លើយរបស់សាក្សីទាំងនេះ ។

១៦. វិធីសាស្ត្ររបស់ចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូងពិតជាមិនបានផ្តល់អ្វីសោះដល់មេធាវីការពារក្តី ។ នៅក្នុងអំឡុងពេលជំនុំជម្រះនេះ លោក នួន ជា មានបំណងចង់លើកឡើងថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីតែគោលបំណងមនុស្សធម៌ទាំងស្រុង ហើយមកទល់ពេលនេះ លោក នួន ជា នៅតែជឿរឿងនេះដែរ ។ ផ្ទុយទៅវិញ ព្រះរាជអាជ្ញាប្រាកដជានឹងជំទាស់នឹងការលើកឡើងបែបនេះ ។ ខ្ញុំសូមសួរលោក/លោកស្រីចៅក្រមថា តើយើងខ្ញុំអាចបង្ហាញលោក/លោកស្រីចៅក្រម (អង្គជំនុំជម្រះសាលាដំបូង) នៅពេលនេះ ក្នុងដំណាក់កាលនេះ ថាស្ថានភាពក្នុងទីក្រុងភ្នំពេញកាលនោះពិតជាអាក្រក់ខ្លាំងមែន រហូតដល់ការជម្លៀសប្រជាជនចេញពីទីក្រុងនេះដែលជាដំណោះស្រាយតែមួយគត់ បានដូចម៉េចទៅ? ខណៈដែលយើងខ្ញុំដែលជាមេធាវីការពារក្តី មិនដែលត្រូវបានគេអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតម្តងណាសោះឡើយ។ ចៅក្រមស៊ើបអង្កេត *មិនបាន* ស៊ើបអង្កេតអោយពួកយើងទេ ហើយមិនតែប៉ុណ្ណោះពេលនេះអង្គជំនុំជម្រះសាលាដំបូង ថែមទាំងបដិសេធមិនកោះហៅសាក្សីដែលបានគាំទ្រការអះអាងរបស់ លោក នួន ជា ទៀតផង ។ យើងពិតជាមានតែបាតដៃទទេ ។

១៧. លោក នួន ជា មានយល់ឃើញថាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺចាំបាច់ដើម្បីបញ្ចៀសវិបត្តិមនុស្សធម៌បន្ថែមទៀត។ ទីក្រុងភ្នំពេញមិនត្រឹមតែគំរាមកំហែងដោយវិបត្តិខ្វះស្បៀងយ៉ាងធ្ងន់ធ្ងរ

ប៉ុណ្ណោះទេ តែមេដឹកនាំកម្ពុជាប្រជាធិបតេយ្យក៏មានជំនឿថា ទីក្រុងនេះនឹងត្រូវរងការទម្លាក់គ្រាប់បែកពីកងទ័ពអាមេរិកទៀតផង។ ម្យ៉ាងវិញទៀតការសន្និដ្ឋានរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ អាចត្រូវបានគេយល់កាន់តែច្រើន បើសិនជាយើងដឹងថា ពួកមេដឹកនាំខ្មែរក្រហមទាំងនោះក៏បានទទួលរងនូវការទម្លាក់គ្រាប់ បែកពីយោធាអាមេរិកាំងចូលក្នុងព្រៃលាក់ខ្លួនរបស់ពួកគេជាច្រើនឆ្នាំជាបន្តបន្ទាប់រហូតដល់សង្គ្រាមបញ្ចប់ ហើយមិនតែប៉ុណ្ណោះប្រជាជនស្លូតត្រង់កម្ពុជានៅតាមជនស្រុកស្រែចំការក៏ទទួលរងពីការទម្លាក់គ្រាប់បែកនេះដែរ។ ប្រសិនបើយើងទទួលស្គាល់ថានេះជា បទពិសោធន៍ដ៏លំបាកបំផុតរបស់មេដឹកនាំខ្មែរក្រហម នោះគេងាយនឹងយល់ពីការភ័យខ្លាចរបស់ពួកគេពីការទម្លាក់គ្រាប់បែករបស់កងយោធាអាមេរិក។ ជាថ្មីម្តងទៀត នេះជាផ្នែកមួយនៃបទពិសោធន៍របស់ប្រជាជនកម្ពុជាដែលមិនបានត្រូវកត់ត្រាចូលក្នុងប្រវត្តិសាស្ត្រ ដូចដែលតុលាការដឹងនោះទេ ។

១៨. លោក នួន ជា បានជឿ និងបន្តជឿមកទល់ថ្ងៃនេះថា គាត់ត្រូវតែមានវិធានការទៅតាមអ្វីដែល គាត់បានធ្វើ ដើម្បីការពារប្រជាជនកម្ពុជាពីការរង់ឈឺចាប់បន្ថែមទៀត និងដើម្បីធានា សន្តិសុខជាតិប្រឆាំងពីគំរាមកំហែងពីក្រុងប្រទេស និងក្រៅប្រទេស ។ វាជាការសំខាន់ ដែលត្រូវកត់សម្គាល់ថា លោក នួន ជា បានជឿ និងបន្តជឿថា អំពើរបស់គាត់គឺចាំបាច់ ដើម្បីបញ្ចៀសភាពទុក្ខវេទនាកាន់តែខ្លាំងថែមទៀត ។

១៩. ការពិចារណាទាំងនេះ គឺពិតជាពាក់ព័ន្ធទៅនឹងចេតនារបស់ លោក នួន ជា ហើយដូចជា លោក/លោកស្រីចៅក្រមទាំងអស់បានដឹង ការពិចារណាមួយក្នុងចំណោមការពិចារណាសំខាន់ៗជាច្រើនក្នុងច្បាប់ព្រហ្មទណ្ឌ គឺជាបញ្ហាទាក់ទងនឹង*ចេតនា*ដែលជាវិធីសាស្ត្ររបស់ចៅក្រមស៊ើបអង្កេត ហើយក្រោយមកអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់យ៉ាងច្បាស់ថាទិដ្ឋភាពណាក៏ដោយដែលយើងនឹងទទួលបានអំពីចេតនារបស់មេដឹកនាំកម្ពុជាប្រជាធិតបតេយ្យ ទាក់ទងនឹងការជម្លៀស ប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក្រោយមកទៀត ការផ្លាស់ទៅលំនៅប្រជាជនទៅតំបន់ផ្សេងៗ នឹងធ្វើឱ្យមានកំហុសឆ្គង និងមិនពេញលេញឡើយ ។ ការជំនុំជម្រះនេះមកទល់ពេលនេះ ខ្ញុំមានអារម្មណ៍ថាយើងកំពុងធ្វើដំណើរឆ្ពោះទៅការបញ្ជាក់អះអាងដ៏សាមញ្ញមួយទៅលើដីកាដំណោះស្រាយ។ អ្នករាល់គ្នាហាក់បីដូចជាចាប់អារម្មណ៍តែការដល់ការកាត់ទោសឱ្យបានលឿន។ ខ្ញុំពិតជាសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូងនឹងរកភស្តុតាងមកបង្ហាញឱ្យឃើញថា ការអះអាងរបស់ខ្ញុំ គឺជាការអះអាងដែលមិនត្រឹមត្រូវ និងផ្តល់ឱកាសឱ្យការពិចារណាពីស្ថាន ភាពដ៏អាក្រក់នៅកម្ពុជានៅមុនឆ្នាំ១៩៧៥ ។

## ការផ្លាស់ទីលំនៅប្រជាជន

២០. រឿងរ៉ាវស្រដៀងគ្នាមួយដូចគ្នានឹងរឿងរ៉ាវអំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ អាច ពិពណ៌នាបាន ទាក់ទងនឹងផ្លាស់លំនៅប្រជាជនពីតំបន់និរតីទៅតំបន់ពាយព្យ ។ អ្នកធ្វើអត្ថាធិប្បាយយជាច្រើនបាន លើកឡើងពីមូលហេតុខុសៗគ្នា ទាក់ទងនឹងការផ្លាស់លំនៅប្រជាជននេះ ។ ប៉ុន្តែ នៅដើមដំបូង នៃការជំនុំជម្រះនេះ វាជាការសំខាន់ក្នុងការកត់សម្គាល់ជាថ្មីម្តងទៀតថា ក្តីកង្វល់ចម្បងបំផុតរបស់ កម្ពុជាប្រជាធិបតេយ្យគឺ*ស្បៀង* ។ កម្ពុជាប្រជាធិបតេយ្យចង់បានបំផុតនោះ គឺចិញ្ចឹមប្រជាជនកម្ពុជា ។ មធ្យាបាយជាក់ស្តែងដើម្បីធានាស្បៀងអោយបានគ្រប់គ្រាន់សម្រាប់ប្រជនជនកម្ពុជាទាំងអស់ គឺ ត្រូវបង្កើនផលិតកម្មស្បៀង ។ *នេះ*គឺជាមូលហេតុដែលនាំឱ្យការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំ ។ គ្មានមូលហេតុអាក្រក់អ្វីទាក់ទងនឹងការជម្លៀសនេះឡើយ ពោលគឺកម្ពុជាប្រជាធិបតេយ្យ ចង់ធ្វើឱ្យ ប្រាកដថាពលករជាច្រើននាក់នឹងរស់នៅក្នុងតំបន់ដែលងាយស្រួលបំផុតក្នុងការផលិតស្បៀង។ ដោយសារតែមូលហេតុនេះហើយ ទើបចាំបាច់ត្រូវតែមានការផ្លាស់ទីលំនៅប្រជាជន ។

២១. ជាថ្មីម្តងទៀត នេះមិនមែនជាការដោះសារទេដែលថា លោក នួន ជា ទើបតែបានពន្យល់ពីបញ្ហានេះ ក្រោយពីរបបខ្មែរក្រហមបានដួលរលំជាយូរមកហើយ។ ខ្ញុំសូមឱ្យលោក/លោកស្រីចៅក្រមពិនិត្យ មើលឯកសារដើមដែលមានតាំងពីពេលនោះមក។ ឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបានគាំទ្រ ការអះអាងរបស់លោក នួន ជា ដែលថាក្តីបារម្ភចំពោះសុខុមាលភាពប្រជាជន គឺជាមូលហេតុដែល នាំឱ្យការផ្លាស់ទីលំនៅប្រជាជន ។

២២. ថ្ងៃនេះ ខ្ញុំនឹងមិនដកស្រង់ឯកសារទាំងនេះចេញពីសំណុំរឿងនោះទេ តែខ្ញុំចង់ពន្យល់ដល់ សាធារណជន ឱ្យបានច្បាស់ថាតើឯកសារទាំងនេះនិយាយពីអ្វីខ្លះ។ ឯកសារទាំងនេះបង្ហាញឱ្យឃើញថាការផ្លាស់ ទីលំនៅប្រជាជន ត្រូវបានធ្វើឡើងក្នុងបំណងល្អ។ មេដឹកនាំ ខ្មែរក្រហមចង់បំលាស់ប្រជាជនឱ្យចេញ ឆ្ងាយពីភាពអត់ឃ្លាន ទៅកាន់កន្លែងដែលងាយស្រួលផលិតស្បៀង។ និយាយម្យ៉ាងវិញ គោលបំណង របស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ ខាងក្រោមនេះគឺជាពាក្យសំដីដែលយកចេញពីឯកសាររបស់ បក្សដែលបានបង្កើតឡើងកាលពីខែកញ្ញា ឆ្នាំ១៩៧៥ “នៅទូទាំងប្រទេស នៅតាមមូលដ្ឋានីមួយៗ យើង ត្រូវជ្រើសរើសទីតាំងដែលអំណោយផល និងល្អបំផុតដើម្បីធ្វើការមុន។ កន្លែងដែលពិបាកបំរុងទុក លើកក្រោយ។ ធ្វើដូច្នេះនឹងនាំឱ្យមាន ការបង្ករបង្កើនផលដំណាំ និងច្រូតកាត់បានលឿន”។ “តើយើង

ត្រូវប្រមូលផ្តុំ កម្លាំងប្រជាជននៅទីណា? យើងត្រូវតែធ្វើបែបនេះនៅទីណាក៏ដោយឲ្យតែដីល្អ ដីមានជីជាតិ និងអំណោយផល មិនមែននៅទីណាដែលដីមិនល្អ និងគ្មានជីជាតិឡើយ” ។

២៣. ក្តីកង្វល់នេះពន្យល់ពីការផ្លាស់ទីលំនៅប្រជាជនទៅកាន់ខត្តរ និងតំបន់ពាយ័ព្យ ដែលជាទីកន្លែងអំណោយផលសម្រាប់ធ្វើកសិកម្ម ហើយហេតុដូច្នេះ តំបន់ទាំងពីរនេះត្រូវទទួល ប្រជាជនច្រើនជាងគេ ។ ជាថ្មីម្តងទៀត សំដីទាំងមិនមែនទើបនិយាយពីមាត់ នួន ជា ក្នុងពេលនេះ តែមូលហេតុទាំងនេះមានសរសេរនៅក្នុងឯកសារប្រវត្តិសាស្ត្រជាច្រើន ដែលនឹងលើកនិយាយក្នុងពេលសវនាការ។ អនុលោមតាមឯកសារទាំងនេះ គោលបំណង មួយក្នុងចំណោមគោលបំណងជាច្រើនរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ចង់លើកកំពស់លក្ខខណ្ឌរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស។ ជាថ្មីម្តងទៀត សំដីទាំងនេះបង្ហាញក្តីកង្វល់ជាចម្បងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ គឺសុខុមភាពរបស់ ប្រជាជន ។

២៤. ដូចគ្នានេះដែរ នៅក្នុងឯកសារមួយផ្សេងទៀត គោលនយោបាយពាណិជ្ជកម្មរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ គឺដើម្បី“បម្រើការរកស៊ីចិញ្ចឹមជីវិតរបស់ប្រជាជនទាក់ទងនឹងសម្ភារៈប្រើប្រាស់ជាមូលដ្ឋាន”។ ជាថ្មីម្តងទៀត ទាំងនេះមិនមែនជាពាក្យសំដីរបស់របបដែលសម្លាប់មនុស្សទេ។ តែនេះគឺជាជាពាក្យសំដីដែលប្រើដោយរបបមួយដែលយកចិត្តទុកដាក់ទៅលើប្រជាជន ។

២៥. ការកត់សម្គាល់ចុងក្រោយ គឺពាក់ព័ន្ធនឹងឯកសារដើមនេះ គឺថាឯកសារទាំងនេះនឹងជួយជំរុះចោលនូវការយល់ដឹងជាទូលំទូលាយមួយទៀតថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាសង្គមកសិកម្មអន់ថយមួយ ។ ការយល់ឃើញនេះខុសឆ្ងាយណាស់! មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់អភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យទៅជាប្រទេសទំនើបមួយដែលមានវិធីស្រាស្ត្រផលិតកម្មទំនើប ហើយប្រជជនគ្រប់រូបអាចទទួលបានចំណីអាហារ និងការព្យាបាលគ្រប់គ្រាន់។ ជាថ្មីម្តងទៀត ប្រសិនជាលោក/លោកស្រីចៅក្រម អានឯកសារដែលជាផ្នែកមួយនៃសំណុំរឿងនេះ លោក/លោកស្រីចៅក្រម នឹងឃើញថាក្តីបារម្ភចំពោះសុខុមលភាពរបស់ប្រជាជន គឺជាបញ្ហាអទិភាពរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។

២៦. ក្នុងបរិបទនេះ គេគួរកត់សម្គាល់ផងដែរថាដីកាដំណោះស្រាយបានគូសបញ្ជាក់ថា “គ្មានហេតុផលណាដែលទទួលយកដោយច្បាប់អន្តរជាតិចំពោះការជម្លៀសប្រជាជនឡើយ”ដីកាដំណោះស្រាយ បានពិភាក្សាអំពីហេតុផលដែលអាចទៅរួចទាំង អស់ចំពោះការជម្លៀសប្រជាជនតាមលក្ខណៈ*ទីទៃពីគ្នា* ហើយបន្ទាប់មកបានច្រានចោលហេតុផលទាំងនោះ។ ប៉ុន្តែនេះមិនមែនជាវិធីសាស្ត្រត្រឹមត្រូវនោះទេ។

តាមពិតមូលហេតុទាំងអស់នៃការជម្លៀសប្រជាជនក្នុងតំបន់ជាច្រើនត្រូវបានធ្វើឡើងក្នុងពេលតំណាលគ្នា ដូច្នេះបញ្ហានេះត្រូវតែលើកយកមកពិចារណា*រួមគ្នា* ។ វាមិនមែនគ្រាន់តែជាការខ្វះខាតស្បៀងក្នុងទីក្រុងភ្នំពេញ ឬគ្រាន់តែជាការគំរាមកំ ហែងដោយការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិក ឬគ្រាន់តែជាស្ថានភាពថែរក្សាសុខភាពទូទៅ ឬគ្រាន់តែគោលបំណងបង្កើនផលិតកម្មកសិកម្មទូទៅ ឬគ្រាន់តែជាការចាំបាច់ដើម្បីទប់ទល់នឹងការគំរាមកំហែងពីប្រទេសវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែគឺកាលៈទេសៈទាំងអស់នេះរួមបញ្ចូលគ្នាដែលនាំទៅដល់ការសម្រេចចិត្តជម្លៀសប្រជាជន។ នេះជារឿងធម្មតាដែលកើតឡើងនៅពេលដែលនរណាម្នាក់គ្រប់គ្រងប្រទេសមួយ។ ក្នុងនាមជាអ្នកដឹកនាំប្រទេស មនុស្សម្នាក់ត្រូវប្រឈមមុខនឹងការលំបាកជាច្រើន ហើយត្រូវធ្វើការសម្រេចចិត្តដោយផ្អែកលើអ្វីដែលខ្លួនពេញចិត្តដើម្បីដោះស្រាយ *ការលំបាកទាំងនោះរួមគ្នា*។ ក្នុងអំឡុងពេលសវនាការនេះ យើងខ្ញុំនឹងពន្យល់បន្ថែមទៀតថាតើហេតុអ្វីបានជាមូលហេតុរួមគ្នាដែលនាំឲ្យមានការជម្លៀសប្រជាជនដូចដែលបានលើកឡើងដោយលោក នួន ជា នាំឲ្យមានការសន្និដ្ឋានថាវាមាន“ហេតុផលដែលទទួលយកដោយច្បាប់អន្តរជាតិ” និងថាការជម្លៀសប្រជាជនគឺជារឿងស្របច្បាប់។

២៧. ឥឡូវនេះ ខ្ញុំសូមកំណត់ការលើកឡើងរបស់ខ្ញុំត្រឹមការសន្និដ្ឋានដែលថាដីកាដំណោះ ស្រាយមិនមានបណងពន្យល់សូម្បីថា តើគោលគំនិតនៃហេតុផលដែលអាចទទួលយក បាននៅក្រោមច្បាប់អន្តរជាតិមានន័យឲ្យប្រាកដថាម៉េច។ ការិយាល័យសហចៅក្រមស៊ើបអង្កេតគួរតែពន្យល់ពីបញ្ហានេះ។ បន្ទាប់មក ការពិចារណាដ៏ម៉ត់ចត់មួយទាក់ទងនឹងហេតុផលដែលអាចទៅរួចនឹងបង្ហាញថារដ្ឋដែលមានអធិបតេយ្យភាព អាចបង្កើតហេតុផលជាច្រើនដើម្បីជម្លៀសប្រជាជនរបស់ខ្លួនដោយស្របច្បាប់។ ឧទាហរណ៍ដ៏ល្អមួយនៅពេលបច្ចុប្បន្ននេះ គឺមាននៅក្នុងប្រទេសចិនដែលនៅទីនោះការកសាងទំនប់ Gerges dam នៅទន្លេ Yangtze បាននាំឲ្យមានការជម្លៀសប្រជាជនដោយបង្ខំចំនួនជាង១លាននាក់។ គេគួរកត់សម្គាល់ផងដែរថាប្រជាជនទាំង នេះមិនបានវិលត្រឡប់មកលំនៅដ្ឋានរបស់ពួកគេវិញឡើយ ព្រោះផ្ទះសម្បែង និងសម្ភារៈដទៃទៀតរបស់ពួកគេនឹងត្រូវទឹកលិច។ ពិតណាស់ គម្រោងនេះទទួលរងការរិះគន់ពីភាគី ជាច្រើន ប៉ុន្តែគ្មាននរណាម្នាក់អះអាងថាប្រទេសចិនគ្មានសិទ្ធិជម្លៀសប្រជាជនរបស់ខ្លួន។ តាមវិធីនេះ នៅក្រោមច្បាប់អន្តរជាតិនោះទេ។ គេក៏គួរកត់សម្គាល់ផងដែរថា នៅក្នុងប្រទេសចិន មូលហេតុនៃការជម្លៀសប្រជាជនមិនមានលក្ខណៈទាក់ទាញគួរឲ្យជឿជាក់ ដូចក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៥ឡើយ។ មូលហេតុនៃការជម្លៀស ប្រជាជនក្នុងប្រទេសចិនគឺទំនប់ Yangtze ត្រូវ

បានកសាងជាពិសេសដើម្បីបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងដើម្បីបង្កើនថាមពលអគ្គិសនី។ សូមប្រៀបធៀបហេតុផលនេះទៅនឹងការគំរាមកំហែងពីភាពអត់ឃ្លាន ជំងឺ និងសង្គ្រាមដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានព្រួយមមុខកាលពីឆ្នាំ១៩៧៥ដែលនាំទៅដល់ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ។

២៨. ម្យ៉ាងវិញទៀត រដ្ឋដែលមានអធិបតេយ្យភាពអាចជម្លៀសប្រជាជននៅលើទឹកដីរបស់ខ្លួនដោយផ្អែកលើមូលហេតុជាច្រើនផ្សេងៗពីគ្នា ហើយរដ្ឋទាំងនោះអាចធ្វើដូច្នេះដោយសារតែគោលបំណងជាច្រើន។ វាអាចជាដោយសារតែគោលបំណងផ្នែកវប្បធម៌ មនោគមន៍វិជ្ជា ឬផ្នែកសេដ្ឋកិច្ច។ ក្នុងស្ថានភាពពិសេសមួយចំនួន រដ្ឋដែលមានអធិតេយ្យភាព គឺស្ថិតក្នុងជម្រើសដែលត្រូវតែធ្វើសេចក្តីសម្រេចទាំងនេះនៅនឹងកន្លែងដោយផ្អែកលើព័ត៌មានមិនពេញលេញ។ គេអាចយល់ស្រុបចំពោះការ សម្រេចបែបនេះ ឬក៏មិនយល់ស្រប ហើយការសម្រេចចិត្តបែបនេះមួយចំនួនអាចទទួលបានលទ្ធផលល្អជាងការសម្រេចិត្តដទៃទៀត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វាមិនមែនជាបទឧក្រិដ្ឋ ប្រឆាំងមនុស្សជាតិឡើយ។

## តួនាទីរបស់ប្រទេសវៀតណាម

២៩. គេគួរកត់សម្គាល់ផងដែរថា ការជ្រើសរើសយកការជម្លៀសប្រជាជនចេញពីទីក្រុង ភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនមកធ្វើជាកម្មវត្ថុនៃការជំនុំជម្រះនេះ ហាក់ដូចជាមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីពិភាក្សាពីតួនាទីរបស់ប្រទេសវៀតណាមឡើយ ។ ប៉ុន្តែលោក នួន ជា គិតថាតួនាទីរបស់វៀតណាមក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្នគឺមានសារៈ សំខាន់បំផុត។ នៅថ្ងៃនេះ លោក/លោកស្រីចៅក្រម បានឮ លោកនួន ជា និយាយបញ្ហាមួយចំនួនអំពីប្រទេសវៀតណាម ។ លោក នួន ជា គិតថាវៀតណាមបានប៉ុនប៉ងជាបន្តបន្ទាប់ ដើម្បីបំផ្លាញកិច្ចខិតខំប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការនាំមកភាពរុងរឿងជូនប្រទេសកម្ពុជា។ លោក នួន ជា គិតថាប្រសិនជាវៀតណាមមិនបានវាយប្រហារកម្ពុជា និងដាក់គិញក្សត់បង្កប់ក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ជាបន្តបន្ទាប់ទេ នោះកម្ពុជាប្រជាធិបតេយ្យអាចក្លាយជារបបមួយដែលសម្បូររុងរឿងទៅហើយ។ ប៉ុន្តែដោយសារតែមហិច្ឆិតាចង់លេបទឹកដី និងចង់មានឥទ្ធិពលក្នុងតំបន់ វៀតណាមបានសម្រេចជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់កម្ពុជា ។ សកម្មភាពជាច្រើនរបស់កម្ពុជាប្រជាធិបតេយ្យ គឺដើម្បីប្រឆាំងនឹងឥទ្ធិពលរបស់វៀតណាម ។

៣០. លោក នួន ជា គិតថាគោលបំណងយ៉ាងជាក់ច្បាស់របស់វៀតណាមនោះគឺការធ្វើសង្គ្រាមតាមព្រំដែន ជាបន្តបន្ទាប់ ដែលជាសញ្ញាណយ៉ាងច្បាស់បញ្ជាក់ពីមហិច្ឆិតារបស់វៀតណាមនៅពេលនោះ។ កម្ពុជា មិនចង់បានសង្គ្រាមនេះទេ តែចង់កសាងប្រទេសរបស់ខ្លួនតែប៉ុណ្ណោះ ។ តែកម្ពុជាគ្មានជម្រើសទេ ។ កម្ពុជាត្រូវតែការពារខ្លួនប្រឆាំងអំពើឈ្លាន ពានរបស់វៀតណាម។ នៅទីបញ្ចប់ វៀតណាមឈ្លានពាន កម្ពុជាដែលជាអំពើរំលោភ បំពានធម្មនុញ្ញអង្គការសហប្រជាជាតិ និងបានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនឆ្នាំក្រោយៗមកទៀត ។

៣១. លោក នួន ជា រំពឹងទុកថា ក្នុងអំឡុងពេលជំនុំជម្រះនេះគាត់នឹងទទួលបានឱកាសបកស្រាយអំពីការគំរាមកំហែងរបស់វៀតណាម។ ជាថ្មីម្តងទៀតការយល់ដឹងពេញលេញពីការ ការគំរាមកំហែងរបស់វៀតណាមដូចដែលមេដឹកនាំខ្មែរក្រហមបានយល់ គឺមានសារៈ សំខាន់ណាស់ ប្រសិនបើអង្គជំនុំជម្រះចង់យល់អំពី និងជាពិសេសចេតនារបស់មេដឹកនាំ កម្ពុជាប្រជាធិបតេយ្យ ។

## សេចក្តីសន្និដ្ឋាន

៣២. លោក/លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់សេចក្តីសន្និដ្ឋានបើករបស់នៅត្រង់នេះ។ ជាថ្មីម្តងទៀត ដើម្បីយល់ឲ្យបានស៊ីជម្រៅពីអំពើរបស់គាត់ ខ្ញុំសូមឲ្យលោក/លោកស្រីចៅក្រមពិចារណាពីបរិបទរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ការពិចារណារបស់លោក/លោកស្រីចៅក្រមលើអង្គហេតុនានា មិនអាចប្រើប្រាស់ឆ្នាំ១៩៧៥ ជាចំណុចចាប់ផ្តើមរបស់វាបានទេ។ ខ្ញុំសូមឲ្យលោក/លោកស្រីចៅក្រម ពិនិត្យមើលអង្គហេតុថយក្រោយមកវិញ ដើម្បីយល់ដឹងស៊ីជម្រៅពីមូលហេតុនានានៅពីក្រោយខ្នងការធ្វើសេចក្តីសម្រេច និងព្រឹត្តិការណ៍នានាដែលបានកើតឡើងក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ លោក នួន ជា នៅតែជឿថាការស៊ើបអង្កេតត្រឹមត្រូវពីចេតនារបស់គាត់ នឹងបង្ហាញថាគាត់មានចេតនាល្អ ហើយថាអំពើរបស់គាត់ គឺបំរើប្រជាជនកម្ពុជា ។